Australian Embassy
Cambodia

NEW ZEALAND
FOREIGN AFFAIRS & TRADE
Manatū Aorere

UNDP

(Energy)Lab

# សេចក្តីប្រកាសព័ត៌មានរួម

*២៤ វិច្ឆិកា ២០២៣*

## អបអរសាទរចំពោះការបិទជាស្ថាពរនៃព្រឹត្តិការណ៍សប្តាហ៍ថាមពលស្អាត ២០២៣

ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ជាថ្ងៃបញ្ចប់នៃព្រឹត្តការណ៍សប្តាហ៍ថាមពលស្អាតសម្រាប់ឆ្នាំ ២០២៣។ ការបិទកម្មវិធីនេះ បានប្រព្រឹត្តិនៅគេហដ្ឋានរបស់ឯកអគ្គរដ្ឋទូតអូស្ត្រាលី លោក ចាស្ទីន វ៉ាយអេត ដោយបានប្រមូលផ្តុំភាគីពាក់ព័ន្ធ និងអ្នកជំនាញក្នុងវិស័យថាមពលក្នុងប្រទេសកម្ពុជា ដើម្បីអបអរសាទរវឌ្ឍភាពនៃថាមពលស្អាតរបស់កម្ពុជា។

វត្តមានចូលរួមដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី  ឯកឧត្តម កែវ រតនៈ រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ឯកឧត្តម ហែម វណ្ណឌី រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងលោកស្រី អាលីហ្សា ឆាកឃី អ្នកតំណាងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ប្រចាំកម្ពុជា បានចូលរួមជាមួយឯកអគ្គរដ្ឋទូតអូស្ត្រាលី លោក ចាស្ទីន វ៉ាយអេត និងលោកណាត្តារុណ ង៉ោ សឺន នាយកប្រចាំប្រទេសរបស់អង្គការអេននីជីឡេប (EnergyLab Cambodia) ក្នុងការបិទកម្មវិធីសប្តាហ៍ថាមពលស្អាតនេះ បញ្ជាក់ពីសារៈសំខាន់នៃថាមពលស្អាតសម្រាប់ការអភិវឌ្ឍន៍ប្រទេស។

សប្តាហ៍ថាមពលស្អាតបានចាប់ផ្តើមដោយផ្តោតលើតួនាទីដែលថាមពលស្អាតត្រូវតែដើរតួក្នុងការផ្តល់សន្តិសុខថាមពលសម្រាប់កម្ពុជា។ ថាមពលពន្លឺព្រះអាទិត្យ និងខ្យល់មានសក្តានុពលយ៉ាងធំធេងសម្រាប់ប្រទេសកម្ពុជា និងអាចកាត់បន្ថយការនាំចូលឥន្ធនៈហ្វូស៊ីល និងអគ្គិសនីពីក្រៅប្រទេស។ ការវិនិយោគថ្មីៗលើថាមពលស្អាតក៏អាចជួយកាត់បន្ថយការបង្កើតថ្មីនូវឥន្ធនៈហ្វូស៊ីលថ្មីដែលមិនចាំបាច់ ដែលនឹងជំរុញឱ្យកម្ពុជាបន្តពឹងផ្អែកលើទីផ្សារឥន្ធនៈហ្វូស៊ីលអន្តរជាតិសម្រាប់ទសវត្សរ៍ខាងមុខ។

តាមរយៈកម្មវិធីចំនួន២២ដែលធ្វើឡើងនៅអំឡុងពេលពេញមួយសប្តាហ៍នេះ ថ្នាក់ដឹកនាំ អ្នកជំនាញ និងសហគ្រិនក្នុងវិស័យថាមពលស្អាតបានចូលរួមស្វែងយល់អំពីប្រធានបទរបស់ព្រឹត្តិការណ៍សប្តាហ៍ថាមពលស្អាតកម្ពុជាឆ្នាំ២០២៣គឺ "សន្តិសុខថាមពល និងអនាគតថាមពលស្អាតរបស់កម្ពុជា"។

កម្មវិធីនីមួយៗបានជជែកពិភាក្សារកដំណោះស្រាយសម្រាប់បញ្ហាសំខាន់ៗមួយចំនួនដូចជា ការកាត់បន្ថយកាបូនផ្នែកឧស្សាហកម្ម ការកំណត់អត្តសញ្ញាណបច្ចេកវិទ្យាដែលចាំបាច់នៅពេលដែលបរិមាណថាមពលស្អាតកើនឡើង និងការស្វែងយល់ពីរបៀបដែលគំរូអាជីវកម្មថ្មីនឹងត្រូវបានបង្កើតឡើងដើម្បីសម្រេចបាននូវគោលដៅប្រសិទ្ធភាពថាមពលរបស់កម្ពុជា។ តួអង្គសំខាន់ៗក្នុងវិស័យថាមពលស្អាត និងការអភិវឌ្ឍន៍ រួមមានចាប់ពីប្រជាពលរដ្ឋក្នុងសហគមន៍តាមបណ្តោយបឹងទន្លេសាប រហូតដល់រដ្ឋលេខាធិការ បានចូលរួមចែករំលែកទស្សនៈវិស័យថ្នាក់ជាតិ ថ្នាក់តំបន់ និងកម្រិតពិភពលោក។

សប្តាហ៍នេះក៏មានមហាជនរាប់ពាន់នាក់ចូលរួមក្នុងកម្មវិធីដែលបើកជាសាធារណៈ រួមមានកម្មវិធីរត់ដើម្បីថាមពលស្អាត ការតាំងពិព័រណ៍សប្តាហ៍ថាមពលស្អាត និងការបញ្ចាំងវីដេអូឯកសារថាមពលស្អាត។ ព្រឹត្តិការណ៍នេះបានជម្រុញសាធារណៈជនមានឱកាសទទួលយកបទពិសោធន៍ដោយផ្ទាល់នូវបច្ចេកវិទ្យាដែលនឹងជំរុញការអភិវឌ្ឍន៍ថាមពលស្អាតរបស់កម្ពុជា។

ឆ្នាំនេះជាឆ្នាំទីប្រាំមួយហើយដែលសប្តាហ៍ថាមពលស្អាតត្រូវបានរៀបចំឡើង និងជាព្រឹត្តិការណ៍ថាមពលស្អាតមួយដ៏ធំ និងទទួលបានការចូលរួមយ៉ាងច្រើនកុះករនៅក្នុងប្រទេសកម្ពុជា។ មេរៀនដែលបានរៀនពេញមួយសប្តាហ៍នេះ នឹងត្រូវប្រើប្រាស់បន្ត ដើម្បីជំរុញដល់វឌ្ឍភាពថាមពលស្អាតនៅក្នុងប្រទេស។

រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ឯកឧត្តម កែវ រតនៈ មានប្រសាសន៍ថា «កម្ពុជាកំពុងទទួលយកថាមពលស្អាត ដើម្បីជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព និងពង្រឹងសន្តិសុខថាមពល។ យើងកំពុងបញ្ចូលគោលការណ៍CARE ដែលជំណាងឲ្យ ថាមពលស្អាត(Clean) តម្លៃសមរម្យ(Affordable) ប្រកបដោយទំនុកចិត្ត(Reliable) និងដោយសមធម៌(Equitable) ទៅក្នុងយុទ្ធសាស្រ្តរបស់យើង។ វិធីសាស្រ្តនេះគឺជាគន្លឹះក្នុងការធានាបាននូវទិដ្ឋភាពថាមពលរួមមួយ ដែលជួយដល់ការអភិវឌ្ឍន៍ប្រទេសជាតិរបស់យើង ការពារបរិស្ថានរបស់យើង និងលើកកំពស់ប្រជាជនរបស់យើង។»

ឯកអគ្គរដ្ឋទូតអូស្រ្តាលី លោក ចាសស្ទីន វ៉ាយអេត បានលើកឡើងថា «មួយសប្តាហ៍នេះ បានប្រព្រឹត្តទៅដោយជោគជ័យគួរឱ្យកត់សម្គាល់។ យើងបានអញ្ជើញអ្នកបង្កើតគោលនយោបាយ និងអ្នកជំនាញដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍។ រួមគ្នាជាធ្លុងមួយ យើងកំពុងគាំទ្រដល់ប្រទេសកម្ពុជា ក្នុងការផ្តល់នូវបណ្តាញថាមពលស្អាត តម្លៃសមរម្យ សុវត្ថិភាពបណ្តាញ និងសម្រេចបាននូវគោលដៅអាកាសធាតុរបស់ខ្លួន។»

លោក ចូណាថាន់ យីងស៍ ឯកអគ្គរដ្ឋទូតនូវែលសេឡង់ប្រចាំកម្ពុជាបានថ្លែងថា «នូវែលហ្សេឡង់មានមោទនភាពដែលអាចគាំទ្រសប្តាហ៍ថាមពលស្អាតកម្ពុជានៅឆ្នាំនេះ ។ យើងឃើញថាព្រឹត្តិការណ៍នេះពិតជាប្រកបដោយថ្លៃថ្លា និងជោគជ័យក្នុងការលើកកម្ពស់ការយល់ដឹងទាក់ទងនឹងសន្តិសុខថាមពល និងមហិច្ឆតាថាមពលស្អាតក្នុងប្រទេសកម្ពុជា។ កម្ពុជាមានសក្តានុពលក្នុងអន្តរកាលថាមពលរបស់ខ្លួន ហើយនូវែលសេឡង់មានសេចក្តីសោមនស្សរីករាយដែលអាចជួយដល់ប្រទេសកម្ពុជាក្នុងការសម្រេចនូវគោលដៅទាំងនេះ។»

លោក ចូណាថាន់ យីងស៍ បានបន្តថា «បញ្ហាប្រឈមសំខាន់មួយដែលត្រូវបានសម្គាល់គឺ ជំនាញរបស់កម្លាំងពលកម្មដែលកំពុងធ្វើការក្នុងវិស័យថាមពលនៅមានកម្រិតនៅឡើយ។ កម្មវិធីមួយរបស់សប្តាហ៍ថាមពលស្អាតក្រោមប្រធានបទ ***ជំនាញសម្រាប់អន្តរកាលថាមពល*** បានបង្ហាញពីកាលានុវត្តភាពសម្រាប់ប្រទេសកម្ពុជា ដោយផ្តល់នូវការយល់ដឹងដ៏មានតម្លៃសម្រាប់ការអភិវឌ្ឍន៍ធនធានមនុស្សរបស់ប្រទេសក្នុងវិស័យថាមពលនេះ។

លោកស្រី អាលីហ្សា ឆាកឃី អ្នកតំណាងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ប្រចាំកម្ពុជាបាននិយាយថា «សប្តាហ៍ថាមពលស្អាតឆ្នាំ២០២៣ បានបញ្ជាក់ឡើងវិញថាអន្តរកាលថាមពល និងការអភិវឌ្ឍន៍ថាមពលគួរតែត្រូវបានចាត់ទុកជាអទិភាព ។ ទោះជាយ៉ាងណាក៏ដោយ ខណៈពេលដែលយើងកំពុងប្រារព្ធព្រឹត្តិការណ៍ដ៏ជោគជ័យមួយនេះ យើងគួរចងចាំថា យើងត្រូវតែបន្តការខិតខំប្រឹងប្រែងក្នុងការបង្កើនល្បឿននៃអន្តរកាលថាមពលរបស់កម្ពុជា។ឱកាសមិនអាចកើតឡើងដោយឯកឯងនោះទេ គឺយើងជាអ្នកបង្កើតវា! ជាមួយគ្នា យើងអាចធានាបាននូវការអន្តរកាលថាមពលប្រកបដោយនិរន្តរភាព សមធម៌ និងយុត្តិធម៌សម្រាប់ទាំងអស់គ្នា។»

លោកណាត្តារុណ ង៉ោ សឺន នាយកប្រចាំប្រទេសរបស់អង្គការអេននឺជីឡេប ( EnergyLab Cambodia ) បានមានប្រសាសន៍ថា «យើងគួរតែចាប់យកសក្តានុពលរបស់ថាមពលពន្លឺព្រះអាទិត្យឲ្យបានពេញលេញមុននឹងយឺតពេល។ កម្ពុជាមានលទ្ធភាព

និងឱកាសដ៏ច្រើនក្នុងការកាត់បន្ថយកាបូនពីបណ្តាញអគ្គិសនីរបស់ខ្លួន ព្រមទាំងសម្រេចបាននូវគោលដៅសេដ្ឋកិច្ច និងជម្រុញឲ្យសន្តិសុខថាមពលរបស់ប្រទេសកាន់តែប្រសើរឡើង។»

សប្តាហ៍ថាមពលស្អាតឆ្នាំ២០២៣ ត្រូវបានរៀបចំឡើងដោយ អង្គការអេនេនីជីឡេប (EnergyLab Cambodia) ក្នុងភាពជាដៃគូ និងសហប្រតិបត្តិការជាមួយនឹងសហស្ថាបនិករួមមាន រដ្ឋាភិបាលអូស្ត្រាលី និង កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងទទួលបានមូលនិធិពីអូស្ត្រាលីតាមរយៈកម្មវិធីភាពជាដៃគូកម្ពុជា អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ (CAPRED) ក្រសួងការបរទេស និងពាណិជ្ជកម្មនូវែលសេឡង់ និងគម្រោងកម្មវិធីផ្លាស់ប្តូរទៅថាមពលព្រះអាទិត្យដែលទទួលបានមូលនិធិពីសហភាពអឺរ៉ុបតាមរយៈកម្មវិធី SWITCH-Asia និងសាធារណរដ្ឋឆែកតាមរយៈទីភ្នាក់ងារអភិវឌ្ឍន៍ឆែក (CzDA)។

### អំពី EnergyLab Cambodia

EnergyLab Cambodia គឺជាអង្គការមិនមែនរដ្ឋាភិបាល ដែលមានគោលដៅបង្កើនបរិមាណថាមពលស្អាតនៅកម្ពុជា ព្រមទាំងជម្រុញឲ្យកម្ពុជាអាចសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ឆ្នាំ ២០៣០ របស់ខ្លួន និងក្លាយជាប្រទេសដែលមានស្ថានភាពចំណូលមធ្យមកម្រិតខ្ពស់។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ៖

https://cleanenergycambodia.org/cleanenergyweek

### សម្រាប់ការសាកសួរព័ត៌មាន សូមទាក់ទង៖

- ស្ថានទូតអូស្ត្រាលី៖ Media.Cambodia@dfat.gov.au
- UNDP: អាត់ ឈុនមួយ អ្នកជំនាញផ្នែកទំនាក់ទំនង នៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ប្រចាំកម្ពុជា, chhunmuoy.ath@undp.org | 077 872 533
- EnergyLab Cambodia: កញ្ញា ញាណ វិភាវី, ប្រធានផ្នែកទំនាក់ទំនង - vipheavy@energylab.asia | 010936357